ចលនមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

ស្ថានភាពសិទ្ធិមនុស្សប្រចាំត្រីមាសទី៣

ខែកក្កដា ដល់ខែកញ្ញា ឆ្នាំ២០២៦

ពីខែកក្កដា ដល់ខែកញ្ញា ឆ្នាំ២០២៦ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) បានតាមដានការរំលោភបំពាន និងការរឹតត្បិតសិទ្ធិមនុស្សចំនួន ៤៧ករណី រួមមានការរឹតត្បិតសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន ការចូលរួមផ្នែកនយោបាយ និងសេរីភាពខាងសមាគម សិទ្ធិដីធ្លី និងសិទ្ធិមានសេរីភាព។ សេរីភាពខាងការបញ្ចេញមតិនៅតែបន្តរងការរឹតត្បិតដូចជាការដាក់ទោសទណ្ឌ ពាក់ព័ន្ធនឹងការបង្ហោះសារលើបណ្តាញសង្គម ការទំនាក់ទំនងជាឯកជនតាមប្រព័ន្ធទឹជីថល និងការបំពេញវិជ្ជាជីវៈសារព័ត៌មាន។ អ្នកនយោបាយបក្សជំទាស់ និងសកម្មជន នៅតែបន្តប្រឈមមុខនឹងចំណាត់ការផ្លូវច្បាប់ ខណៈដែលក្តីបារម្ភអំពីសិទ្ធិដីធ្លី និងបរិស្ថាន នៅតែជាបញ្ហាធំដដែល។

ខាងក្រោមនេះ គឺជាទិដ្ឋភាពទូទៅនៃការរំលោភបំពានដែល ម.ស.ម.ក បានកត់ត្រាៈ

សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពសារព័ត៌មាន

ម.ស.ម.ក បានកត់ត្រាចំនួន ២៥ ករណី ពាក់ព័ន្ធនឹងការរឹតត្បិតលើសេរីភាពខាងការបញ្ចេញមតិ និងសេរីភាពសារព័ត៌មាន។ ច្បាប់ព្រហ្មទណ្ឌត្រូវបានប្រើប្រាស់ទៅលើការបង្ហោះសារលើបណ្តាញសង្គម ការសន្ទនាតាមទូរស័ព្ទ និងសារឯកជន ការថតរូប និងការបំពេញវិជ្ជាជីវៈសារព័ត៌មាន។ អ្នកសារព័ត៌មានអនឡាញ លោក ហែម វណ្ណា ត្រូវបានផ្តន្ទាទោសពន្ធនាគារយៈពេល ៦ ខែ ប៉ុន្តែទោសនេះត្រូវព្យួរ ក្រោមបទញុះញង់ និងបទស្តាប់ ឬថតពាក្យសំដីឯកជន។ ពលរដ្ឋអ្នកសារព័ត៌មាន និងជាសកម្មជនសង្គម លោក ជា វុទ្ធី ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារយៈពេល ១៨ ខែ ពីបទញុះញង់ ពាក់ព័ន្ធនឹងសារដែលបានបង្ហោះនៅក្នុងក្រុមជាឯកជន។ ចៅសង្កាត់រងទី២មួយរូប ដែលជាបេក្ខជនជាប់ឆ្នោតមកពីគណបក្សភ្លើងទៀន ត្រូវបានចាប់ខ្លួន និងចោទប្រកាន់ពីបទញុះញង់ និងប្រមាថ ពាក់ព័ន្ធនឹងការសន្ទនាតាមទូរស័ព្ទជាឯកជន។ ការរឹតត្បិតលើការបញ្ចេញមតិជាសាធារណៈ និងឯកជន មានភាពលេចធ្លោគួរឱ្យកត់សំគាល់នៅក្នុងត្រីមាសនេះ។

សិទ្ធិដីធ្លី និងបរិស្ថាន

ករណីចំនួន ១៦ ពាក់ព័ន្ធនឹងសិទ្ធិដីធ្លី និងបរិស្ថាន រួមមានការចោទប្រកាន់ពីបទញុះញង់ និងបរិហារកេរ្តិ៍លើអ្នកតស៊ូមតិដីធ្លី ការដាក់សម្ពាធលើអ្នកសារព័ត៌មានដែលរាយការណ៍អំពីការកេងប្រវ័ញ្ចធនធានធម្មជាតិខុសច្បាប់ និងការបណ្តេញចេញដោយបង្ខំ។ កាលពីខែសីហា ប្រជាពលរដ្ឋរស់នៅក្នុងសង្កាត់លេខ ១ ក្រុងព្រះសីហនុ ត្រូវបានបណ្តេញចេញដោយបង្ខំ ហើយផ្ទះសម្បែងរបស់ពួកគាត់ត្រូវបានវាយកម្ទេចចោល ដែលឆ្លុះបញ្ចាំងពីអសន្តិសុខលើសហគមន៍កំពុងប្រឈមមុខនៅក្នុងជម្លោះដីធ្លី ដែលសហគមន៍អះអាងថាបានកាន់កាប់ដីនេះយូរមកហើយ តែត្រូវបានអាជ្ញាធរជំទាស់។ លើសពីនេះ តុលាការកំពូលបានតម្កល់ទោសអ្នកការពារសិទ្ធិមនុស្ស លោក កើត សារ៉ាយ ពាក់ព័ន្ធនឹងការតស៊ូមតិផ្នែកសិទ្ធិដីធ្លីរបស់លោកផងដែរ។ លោកនៅតែបន្តជាប់ពន្ធនាគារ ដោយអនុវត្តទោសជាប់ពន្ធនាគារយៈពេល ៤ ឆ្នាំ ទោះបីជាក្រុមការងារអង្គការសហប្រជាជាតិស្តីពីការឃុំឃាំងខ្លួនដោយឥតច្បាប់បានរកឃើញថា ការឃុំខ្លួនរូបលោកគឺមានលក្ខណៈតាមអំពើចិត្ត។

ការចូលរួមផ្នែកនយោបាយ និងសេរីភាពខាងសមាគម

ករណីយីឃាតាមផ្លូវច្បាប់ចំនួន ៣ ករណី លើអ្នកនយោបាយបក្សប្រឆាំង អាជ្ញាធរមូលដ្ឋាន និងសកម្មជននយោបាយ។ ថ្នាក់ដឹកនាំគណបក្សកម្លាំងជាតិ គឺលោក សុក ហុន និងលោក សន ង៉ែត ត្រូវបានចាប់ខ្លួន និងចោទប្រកាន់ពីបទក្លែងបន្លំ និងប្រើប្រាស់លិខិតក្លែង ក្នុងរយៈពេលមិនដល់មួយខែផងបន្ទាប់ពីត្រូវបានតែងតាំងជាថ្នាក់ដឹកនាំនៅក្នុងសង្កាត់ស្ទឹងមានជ័យ រាជធានីភ្នំពេញ។ លោក ចាក់ សារ៉ាយ ប្រធានយុវជនគណបក្សកម្លាំងជាតិ ត្រូវបានចាប់ខ្លួន និងឃុំខ្លួនពីបទរួមគំនិតក្បត់ និងញុះញង់ បន្ទាប់ពីបានចែករំលែកការបង្ហោះសារនៅលើបណ្តាញសង្គមហ្វេសប៊ុក ខណៈដែលសាលាឧទ្ធរណ៍បានតម្កល់ទោស លោក ទៀវ វណ្ណុល ប្រធានគណបក្សភ្លើងទៀន ពីបទបរិហារកេរ្តិ៍។

សិទ្ធិមានសេរីភាព

ម.ស.ម.ក បានកត់ត្រា ចំនួន ៣ ករណី ពាក់ព័ន្ធនឹងការបដិសេធសំណើសុំនៅក្រៅឃុំ រួមជាមួយ នឹងការចាប់ខ្លួន និងទោសពន្ធនាគារជាច្រើនករណីទៀតទៅលើអ្នកសារព័ត៌មាន សកម្មជន និងបុគ្គលផ្សេងទៀត ដែលប្រើប្រាស់សេរីភាពមូលដ្ឋានរបស់ខ្លួន។ កាលពីខែសីហា សាលាឧទ្ធរណ៍ភ្នំពេញ បានបដិសេធសំណើសុំនៅក្រៅឃុំរបស់អ្នកសារព័ត៌ មានពលរដ្ឋ និងជាអ្នកការពារសិទ្ធិមនុស្ស កញ្ញា ហឹម មុំ ខណៈដែលនៅខែកញ្ញា សាលាដំបូងរាជធានីភ្នំពេញ បានផ្តន្ទាទោស កញ្ញាឱ្យជាប់ពន្ធនាគារ រយៈពេល ២ ឆ្នាំ ពីបទញុះញង់បង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម និងប្រមាថ ពាក់ព័ន្ធនឹងការបង្ហោះសារនៅលើបណ្តាញសង្គមហ្វេសប៊ុក។

CC BY NC SA
តុលា ២០២៦